# ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៥៧

## ស្ដីពី
## ការបង្កើតគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក ហៅកាត់ថា គ.ជ.ប.ព. ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មការជាតិយូណេស្កូកម្ពុជា ដើម្បីការពារ និងអភិវឌ្ឍសម្បត្តិធម្មជាតិនិងសម្បត្តិវប្បធម៌ជាតិទាំងរូបីទាំងអរូបីក្នុងក្របខណ្ឌអន្តរជាតិ។

**មាត្រា២.-**

គ.ជ.ប.ព.មានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| -ទីប្រឹក្សាជាន់ខ្ពស់មួយរូប | ប្រធាន |
| -តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |

ROYAUME DU CAMBODGE * LE MINISTRE - PALAIS ROYAL

| | |
|---|---|
| -តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| -តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| -តំណាងអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិ នៃប្រាសាទព្រះវិហារ | សមាជិក |
| -តំណាងអាជ្ញាធរអប្សរា | សមាជិក |
| -តំណាងគណៈកម្មការជាតិយូណេស្កូកម្ពុជា | សមាជិក |
| -នាយកសារមន្ទីរជាតិភ្នំពេញ | សមាជិក |
| -នាយកសារមន្ទីរព្រះនរោត្តម សីហនុ អង្គរ | សមាជិក |

សមាសភាពជាក់ស្ដែងនៃគ.ជ.ប.ព.ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

គ.ជ.ប.ព.អាចមានឥស្សរជន ឬ អ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួនជាទីប្រឹក្សាជាន់ខ្ពស់ ឬ ជាទីប្រឹក្សា។

**មាត្រា៤.-**

គ.ជ.ប.ព.មានតួនាទី និងភារកិច្ចដូចតទៅ ÷

-តំណាងឱ្យព្រះរាជាណាចក្រកម្ពុជានៅក្នុងការប្រជុំស្របតាមលក្ខន្តិកៈឬការប្រជុំបច្ចេកទេសដែលទាក់ទងនឹងការអនុវត្តអនុសញ្ញាឆ្នាំ ១៩៧២ និងឆ្នាំ ២០០៣

-ពិនិត្យតាមដានការដាក់បញ្ចូលឬការវាយតម្លៃរបាយការណ៍ស្ថានភាពនៃការអភិរក្សសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិទាំងរូបី ទាំងអរូបីដែលបានចុះបញ្ជីបេតិកភណ្ឌពិភពលោករួចហើយ

-ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអន្តរជាតិជាមួយគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោកនៃប្រទេសនានា និងការពារចំពោះមុខស្ថាប័នវប្បធម៌អន្តរជាតិ នូវជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រងសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិទាំងរូបី ទាំងអរូបី

-អនុវត្តគ្រប់សកម្មភាពដើម្បីរំលេច និងលើកកម្ពស់រាល់តម្លៃជាសកល និងដោយឡែកនៃបេតិកភណ្ឌធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ខ្មែរទាំងរូបី ទាំងអរូបីនៅទូទាំងពិភពលោក

-សហការជាមួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ ដើម្បីជំរុញការងារអភិរក្សឱ្យមានប្រសិទ្ធភាពនិងការផ្សព្វផ្សាយក្នុងមជ្ឈដ្ឋានជាតិ និងអន្តរជាតិ

-រៀបចំផែនការសកម្មភាពស្ដីពីការអភិរក្សសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិទាំងរូបី ទាំងអរូបីដែលបានចុះបញ្ជីបេតិកភណ្ឌពិភពលោករួចហើយ និងការវាយតម្លៃសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ផ្សេងៗទៀត ដើម្បីស្នើចុះបញ្ជីបេតិកភណ្ឌពិភពលោក

-ធ្វើរបាយការណ៍អំពីបញ្ហាទាក់ទងនឹងបេតិកភណ្ឌពិភពលោក និងរបាយការណ៍ស្តីពីសកម្មភាពរបស់គណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោកតាមការកំណត់ជូនរាជរដ្ឋាភិបាល

-បំពេញភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៥.-**

គ.ជ.ប.ព.ត្រូវប្រជុំសាមញ្ញយ៉ាងតិច០៤(បួន) ដងក្នុងមួយឆ្នាំ និងប្រជុំវិសាមញ្ញតាមការចាំបាច់ តាមការអញ្ជើញរបស់ប្រធាន។

គ.ជ.ប.ព.មានសិទ្ធិអញ្ជើញលេខាធិការអចិន្ត្រៃយ៍ផ្នែកវិទ្យាសាស្ត្រ នៃគណៈកម្មាធិការវប្បធម៌អន្តរជាតិសម្រាប់អង្គរ ប្រធានផ្នែកវប្បធម៌និងបេតិកភណ្ឌនៃការិយាល័យយូណេស្កូភ្នំពេញ ឥស្សរជន និងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធមកចូលរួមប្រជុំរបស់ខ្លួន។

**មាត្រា៦.-**

គ.ជ.ប.ព.មានលេខាធិការដ្ឋាននៅគណៈកម្មការជាតិយូណេស្កូកម្ពុជា ដែលដឹកនាំដោយលេខាធិការ០១(មួយ)រូប។ លេខាធិការដ្ឋាននេះអាចប្រើប្រាស់មន្ត្រីរបស់គណៈកម្មការជាតិយូណេស្កូកម្ពុជាតាមការចាំបាច់។

**មាត្រា៧.-**

គ.ជ.ប.ព.មានប្រភពធនធានថវិកាមកពី ÷

-ថវិកាជាតិក្នុងកញ្ចប់ថវិការបស់គណៈកម្មការជាតិយូណេស្កូកម្ពុជានៅក្នុងក្របខណ្ឌថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី

-ហិរញ្ញប្បទានសហប្រតិបត្តិការពីក្នុង និងក្រៅប្រទេសដែលផ្តល់ដោយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា។

**មាត្រា៨.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩

៣៧ល.០៩០៧.៧៦៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៧០៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុង ជិនកេន**